**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

## ជូនចំពោះ

## លោកស្រី រី សុគុណ្ណា និងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីសោកស្តាយរញ្ជួយក្រៃលែង ដោយបានទទួលដំណឹងថា **ឯកឧត្តម អៀម សារុំ** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ បានទទួលមរណភាពនៅថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ០០និង២នាទី លែងអាធ្រាត្រ ក្នុងជន្មាយុ ៧១ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាអនេកប្បការជាមួយលោកស្រី និងក្រុមញាតិគ្រួសារ ចំពោះការបាត់បង់ **ឯកឧត្តម អៀម សារុំ** ដែលជាឪពុក និងជីតាជាទីគោរពស្រលាញ់របស់ខ្លួន។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ **ឯកឧត្តម អៀម សារុំ** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកស្រី** និងក្រុមគ្រួសារ មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ព្រំ សុខា